# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាជាមួយអដ្ឋិធាតុរបស់សន្ត លូវីស និងសន្តី ហ្សឺលី ម៉ាតាំង
# ព្រែកឫស្សី ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩
## ប្ដីប្រពន្ធដ៏វិសុទ្ធ

**អត្ថបទទី១៖ ថេស្សាឡូនិក ទី១ ១,១-៥,៨-១០**

នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ជាព្រះបិតារបស់យើង យើងនឹកចាំអំពីកិច្ចការដែលបងប្អូនបានធ្វើដោយជំនឿ អំពីការនឿយហត់ដែលបងប្អូនបំពេញ ដោយចិត្តស្រឡាញ់ និងអំពីការស៊ូទ្រាំរបស់បងប្អូន ដោយចិត្តសង្ឃឹមលើព្រះយេស៊ូគ្រីស្តជាអម្ចាស់នៃយើង។ ១ថស ១,៣

**ដំណឹងល្អ៖ ម៉ាថាយ ២៣,១៣-២២**

នែ៎! ពួកបណ្ឌិតខាងវិន័យ* និងពួកផារីស៊ី*ដ៏មានពុតអើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះអ្នករាល់គ្នាបិទទ្វារ មិនឲ្យមនុស្សចូលទៅក្នុងព្រះរាជ្យ*នៃស្ថានបរមសុខ* អ្នករាល់គ្នាមិនត្រឹមតែមិនបានចូលខ្លួនឯងប៉ុណ្ណោះទេ គឺថែមទាំងរារាំងអ្នកដែលចង់ចូលមិនឲ្យគេចូលទៀតផង។ មថ ២៣,១៣

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ជាពេលវេលាយ៉ាងពិសេសដោយសារនៅក្នុងនេះមានធាតុរបស់ឪពុកម្ដាយសន្តីតេរេសា ម្ដាយគាត់ឈ្មោះ ហ្សឺលី ម៉ាតាំង និងឪពុកគាត់ឈ្មោះ លូវីស ម៉ាតាំង។ ទាំងពីរនាក់ជាប្ដីប្រពន្ធប្លែក គេជាយុវនារីម្នាក់និងជាបុរសម្នាក់ដែលកំពុងគិតថាគេចង់ធ្វើជីវិតលើព្រះជាម្ចាស់ ម្នាក់ចង់ធ្វើជាបងស្រី ម្នាក់ចង់ធ្វើជាបូជាចារ្យ។ ប៉ុន្តែ ក្រោយមកគេកំពុងរៀបចំខ្លួនដើម្បីធ្វើជីវិតលើព្រះជាម្ចាស់ក៏ឃើញថាធ្វើជាបងស្រីមិនបាន ធ្វើជាលោកឪពុកមិនបាន ដូច្នេះគេចាប់ផ្ដើមទៅរកការងារធ្វើ។ លូវីស គាត់ជាជាងនាឡិការ និងហ្សឺលី គាត់ជាអ្នកប៉ាក់ ថ្ងៃមួយគេបានជួបគ្នានៅលើស្ពាន ហើយគេធ្លាក់នៅក្នុងស្នេហាភ្លាមៗបីខែក្រោយមកគេរៀបការ។ គេមានកូន៩នាក់ បានស្លាប់៤មុនស្លាប់ ដោយសារសម័យថ្នាំក៏ខ្វះ គ្រូពេទ្យក៏ខ្វះ ជីវិតក៏ក្រ តែគាត់បានខិតខំចិញ្ចឹមអស់ពីសមត្ថភាពកូនស្រី៥នាក់។ នេះជាគ្រួសារមួយយ៉ាងពិសេស ឪពុកគាត់ចូលចិត្តយកពេលវេលាអធិដ្ឋានស្ងៀមស្ងាត់ គាត់ធ្វើការយ៉ាងនឿយហត់ដើម្បីចិញ្ចឹមគ្រួសារ ប៉ុន្តែគាត់មិនដែលភ្លេចព្រះជាម្ចាស់ទេ។ គាត់ដឹងថាជីវិតរបស់គាត់បានទទួលមកពីព្រះជាម្ចាស់ សេចក្ដីស្រឡាញ់ដែលគាត់មានរវាប្រពន្ធនិងប្ដីមកពីព្រះជាម្ចាស់ កូនៗដែលបានទទួលទាំងកូននៅរស់ក្ដីស្លាប់ក្ដីមកពីព្រះជាម្ចាស់។ ជារៀងរាល់ថ្ងៃ គាត់យកពេលអធិដ្ឋាននិងនៅក្នុងផ្ទះគាត់ គាត់បានរៀបចំបន្ទប់មួយយ៉ាងពិសេសដើម្បីអធិដ្ឋានតាំងព្រះកាយ ដើម្បីនឹកឃើញដល់ព្រះជាម្ចាស់ដែលបានប្រទានជីវិត ជីវិតសម្រាប់គាត់ផ្ទាល់ ជីវិតជាប្ដីប្រពន្ធ ជីវិតជាឪពុកម្ដាយ និងជីវិតកូនៗរបស់គាត់ដែលគាត់ស្រឡាញ់កូនទាំងស្ថានបរមសុខ និងកូនស្រី៥នាក់ដែលគាត់កំពុងចិញ្ចឹម។

ហ្សីលី គាត់យកចិត្តទុកដាក់ជាមេផ្ទះ ថែរក្សាផ្ទះ ថែរក្សាប្តី ថែរក្សាកូន យកពេលជាមួយកូនដើម្បីអប់រំ ដើម្បីអប់រំចំណេះដឹង និងអប់រំឲ្យកូនៗចេះស្រឡាញ់ព្រះយេស៊ូ។ជារៀងរាល់ពេលយប់យកពេលវេលាដើម្បីអធិដ្ឋានជាមួយកូន ឲ្យកូនចេះគូសសញ្ញាឈើឆ្កាង ឲ្យកូនចេះអធិដ្ឋានឱព្រះបិតា ឲ្យកូនស្គាល់ព្រះយេស៊ូ ឲ្យកូនស្គាល់ព្រះនាងម៉ារី។ កូនស្រី៥នាក់ ដោយសារឪពុកនិងម្តាយបន្តិចម្តងៗចាប់ផ្តើមភ្ជាប់ជាមួយព្រះជាម្ចាស់ រហូតកូនស្រីទាំង៥នាក់ទៅជាដូនជី។ គ្រួសារនេះប្លែកដោយសារព្រះជាម្ចាស់បានជ្រើសរើស ក្រោយមកព្រះសហគមន៍បានឃើញថាប្តីប្រពន្ធនេះគេបានការអស្ចារ្យនៅក្នុងជីវិតជារៀងរាល់ថ្ងៃ ដោយស្រឡាញ់ព្រះជាម្ចាស់ ដោយរស់នៅជាប្តីព្រន្ធចេះស្រឡាញ់គ្នាទៅវិញទៅមក ចេះគោរពគ្នាទៅវិញទៅមក ដោយយកចិត្តទុកដាក់ថែរក្សាកូនរបស់ពួកគេ ដោយស្រឡាញ់កូនរបស់ពួកគេយ៉ាងខ្លាំង ដោយណែនាំឲ្យកូនរបស់គេមានចំណេះដឹង ដោយសុខចិត្តនៅពេលកូនធំល្មមឲ្យទៅឆ្ងាយពីផ្ទះដើម្បីទៅរៀន យកចិត្តទុកដាក់ ដើម្បីរកស៊ីយកលុយចិញ្ចឹមកូន។

នេះ ជាជីវិតធម្មតានៅក្នុងការគស៊ូ ជីវិតធម្មតានៅក្នុងការស្រឡាញ់ប្តីប្រពន្ធនិងស្រឡាញ់កូន ជីវិតធម្មតានៅក្នុងការស្រឡាញ់ព្រះជាម្ចាស់។ ព្រះសហគមន៍បានឃើញថា ទាំងពីរនាក់មិនធម្មតាទេហ្សីលី បានស្លាប់នៅអាយុ៤៦ឆ្នាំដោយសារជំងឺមហារីកសុដន់ នៅពេលនោះតេរេសាមានអាយុបួនឆ្នាំ។ ក្រោយមក ឪពុកគាត់បានយកចិត្តទុកដាក់ចិញ្ចឹមកូនទាំង៥នាក់ ដោយថែរក្សា ស្រឡាញ់ និងបន្តិចម្តងៗគាត់ចាស់ទៅៗគាត់ចាប់ផ្តើមវង្វេងស្មារតី ប៉ុន្តែនៅពេលគាត់មានស្មារតីគឺនឹកឃើញព្រះជាម្ចាស់។ សន្តីតេរេសា ថាឪពុកគាត់ជាព្រះមហាក្សត្ររបស់គាត់ គាត់ស្រឡាញ់ឪពុកគាត់មែនទែន ដោយសារគាត់ឃើញរបៀបដែលឪពុកស្រឡាញ់គាត់។ នៅពេលសន្តីតេរេសា សុំចូលនៅក្នុងអារាមការម៉ែលជាកន្លែងសម្ងាត់ ចេញឆ្ងាយពីគ្រួសារឪពុកគាត់ឈឺចិត្តដែរ ដោយសារគាត់សប្បាយចិត្តជាមួយកូនពៅរបស់គាត់ ប៉ុន្តែគាត់សុខចិត្តធ្វើតាមអ្វីដែលព្រះជាម្ចាស់បានជ្រើសរើស។

ថ្ងៃនេះ យើងមានយុវជន យើងមានកូនក្មេង យើងមានឪពុកម្តាយ យើងមានលោកតាលោកយាយ ជាពេលវេលាមួយដើម្បីអធិដ្ឋានទូលអង្វរសុំព្រះជាម្ចាស់ជួយយើង ដើម្បីឲ្យយើងទាំងអស់គ្នាយកចិត្តទុកដាក់ទៅជាឪពុកល្អ ទៅជាម្តាយយ៉ាងល្អ ទៅជាប្តីប្រពន្ធដែលចេះស្រឡាញ់គ្នាគោរពគ្នាទៅវិញទៅមក និងយកចិត្តទុកដាក់ថែរក្សាកូនៗ ដើម្បីឲ្យគ្រួសារយើងអាចរកឃើញសេចក្តីសុខ ភាពកក់ក្តៅនិងសេចក្តីស្រឡាញ់។ ហ្សីលី គាត់មកពីគ្រួសារក្រីក្រមែនទែន ម្តាយគាត់អត់ស្រឡាញ់សោះ ប៉ុន្តែនៅពេលហ្សីលី គាត់ធ្វើជាម្តាយគាត់បានយកចិត្តទុកដាក់ជាមួយកូនគាត់។ ជួនកាលយើងមានបទពិសោធន៍ខ្លះដែរនៅក្នុងគ្រួសារយើង ជួនកាលឪពុកយើង

ចោលម្តាយ ឪពុកយើងវៃម្តាយ ជួនកាលម្តាយយើងទៅឆ្ងាយ ជួនកាលយើងអត់មានឪពុកម្តាយ ជួនកាលឪពុកម្តាយអត់ចេះមើលយើង ជួនកាលឪពុកម្តាយឈ្លោះគ្នា...។ ប៉ុន្តែនៅថ្ងៃអនាគត់នៅពេលយើងកសាងគ្រួសារកុំឲ្យយើងអស់សង្ឃឹម យើងយកចិត្តទុកដាក់ថែមទៀតដោយនឹកឃើញរបៀបដែលព្រះជាម្ចាស់ស្រឡាញ់យើង ដោយនឹកឃើញព្រះនាងម៉ារីនិងសន្តយ៉ូសែបដែលជាគ្រួសារដ៏វិសុទ្ធ ដោយនឹកឃើញដល់គ្រួសាររបស់សន្តីតេរេសាដោយដឹងហ្សីលី គាត់ឆ្លងទុក្ខលំបាកខ្លាំងនៅក្នុងគ្រួសាររបស់គាត់។ ប៉ុន្តែពេលគាត់ទៅជាម្តាយគាត់ចេញអស់ពីសេចក្តីស្រឡាញ់ដែលគាត់មានក្នុងចិត្ត ដោយសារគាត់មិនចង់ឲ្យគ្រួសារគាត់ កូនគាត់មានបទពិសោធន៍ដូចគាត់ជាមួយឪពុកម្តាយគាត់ គាត់ចង់ឲ្យកសាងគ្រួសារថ្មីដែលមានសេចក្តីសុខ។ គាត់បានជោគជ័យ ដោយព្រះជាម្ចាស់បានថែរក្សាដើម្បីឲ្យគ្រួសារនេះទៅជាគំរូមួយ និងលើកទឹកចិត្តយើងឲ្យយើងទៅមុខទៀត។

ដូច្នេះថ្ងៃនេះ យើងអរព្រះគុណព្រះជាម្ចាសដែលណែនាំឲ្យទាំងពីរនាក់មកព្រះសហាគមន៍របស់យើង ដោយសារប្តីប្រពន្ធនេះជាប្តីប្រពន្ធរវល់ណាស់ ខ្ញុំបានស្នើសុំពីរឆ្នាំមុនរវល់មែនទែនធ្វើដំណើរពីប្រទេសមួយទៅប្រទេសមួយ។ ដូច្នេះ យើងសប្បាយចិត្តដោយសារពេលនេះឆ្លៀតឱកាសដើម្បីមកដល់ប្រទេសកម្ពុជាបីសប្តាហ៍។ នេះ ជាឪកាសមួយដើម្បីទទួលពរ ដើម្បីទទួលផល ដើម្បីទទួលកម្លាំងរស់នៅក្នុងសេចក្តីសុខ និងខិតខំដើម្បីកសាងគ្រួសាររបស់យើង។ ទាំងអ្នកអត់ទាន់រៀបការក្តី អ្នករៀបការហើយឲ្យយើងគិតទៅ គ្រួសារខ្ញុំត្រូវការទៅជាគ្រួសារដ៏សុខសាន្ត ដូច្នេះថ្ងៃនេះឱកាសមួយដើម្បីអធិដ្ឋានស្ងៀមស្ងាត។ នៅទីនេះ យើងមានជញ្ជៀនពីរដើម្បីនឹកឃើញដល់អាពាហ៍ពិពាហ៍យើង នឹកឃើញដល់តម្លៃនៃអាពាហ៍ពិពាហ៍ដោយដឹងថាព្រះជាម្ចាស់ស្រឡាញ់យើងមែនទែន និងចង់ឲ្យគ្រួសាររបស់យើងពោរពេញដោយសេចក្តីសុខ ជាគ្រួសារនៅក្នុងព្រះសហាគមន៍និងគ្រួសារនីមួយៗដែ។ នៅពេលនេះ យើងស្ងៀមស្ងាត់អធិដ្ឋានទូលអង្វរព្រះជាម្ចាស់តាមរយៈសន្តលូវីស និងសន្តីហ្សីលី ឲ្យជីវិតរបស់យើងពីមួយថ្ងៃទៅមួយថ្ងៃភ្ជាប់នឹងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និងណែនាំឲ្យយើងរកឃើញសេចក្តីស្រឡាញ់សម្រាប់ជីវិតយើងផ្ទាល់។ អាម៉ែន៕